Civil society Links and Empowerment for Socially Inclusive Development in Ratanakiri



# គោលការណ៍យុទ្ធសាស្ត្រនៃខ្សែសង្វាក់តម្លៃដំឡូងមី ក្នុងខេត្តរតនគិរី ប្រទេសកម្ពុជា


***ILS LEDA***



ការសិក្សានេះត្រូវបានចងក្រងដោយដោយអ្នកជំនាញរបស់ ILSLEDA ក្នុងក្របខ័ណ្ឌនៃគម្រោង "CLESIDRA: ការចងបណ្ដាញ និងការពង្រឹងសង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍន៍សង្គមបែបបរិយាបន្ន ក្នុងខេត្តរតនគិរី" ដែលសហការផ្ដល់មូលនិធិដោយសហភាពអឺរ៉ុប។


*ខែកញ្ញា 2024*

FELCOSUMBRIA Associazione di Comuni per lo Sviluppo Sostenibile

## ជំពូកទី៥ គោលការណ៍យុទ្ធសាស្ត្រសំដៅការប្រកួតប្រជែង និងការអភិវឌ្ឍន៍បែបបរិយាបន្ន

### *5.1.* វិធីសាស្ត្រក្នុងការបង្កើតគោលការណ៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃជំនួសមី

ការប្រើប្រាស់វិធីសាស្ត្រ រ៉េស្កូ(RESCO) សម្រាប់ការបកស្រាយលម្អិតនៃគោលការណ៍ណែនាំជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ ប្រើប្រាស់ធាតុចូលដែលដំណើរការពីការវាយតម្លៃ រ៉េស្កូ(RESCO) (សម្ភាសន៍) ពីការវិភាគនៃភាពបន្ទាប់បន្សំ និងពីការពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងចាត់ថ្នាក់។

ធាតុចូលទាំងអស់នេះសំដៅទៅលើសូចនាករនៃចំនុចអថេរនីមួយៗដែលឆ្លើយតបទៅនឹងកត្តារបស់វា បើទោះបីជាវាវិជ្ជមាន (ចំណុចខ្លាំង) ឬអវិជ្ជមាន (ចំណុចខ្សោយ) ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។




សកម្មភាពជាយុទ្ធសាស្ត្រ គួរតែត្រូវបានដោះស្រាយដើម្បី៖

a. រក្សាចំនុចខ្លាំងក្នុងរយះពេលយូរ

b. ដកចេញនូបចំនុចខ្សោយព្រោះវាជាឧបសគ្គដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ

វិធីសាស្ត្ររ៉េស្កូ(RESCO) ប្រើក្បួនដោះស្រាយដ៏សាមញ្ញមួយសម្រាប់ការទាញយកសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់ "ចំនុចអថេរ" នីមួយៗដែលត្រូវគ្នានឹង "កត្តា" ផ្សេងៗគ្នា។

ក្បួនខ្នាតរបស់វាគឺបែបនេះ៖

$Sa = f(V_{i,j}, Fa_n)$

*Sa= Strategic Actions យុទ្ធសាស្ត្រសកម្មភាព*

*$V_{i,j}$= Variable "i" of the Component "j" ចំនុចអថេរ*

*$Fa_n$= Factor "n" កត្តា*

## 5.2. ពីសក្ដានុពលនិងតម្រូវការ ទៅជាសកម្មភាព

សក្ដានុពលនិងតម្រូវការសំខាន់ៗដែលសំដៅលើកត្តានីមួយៗ និងអថេរដែលត្រូវគ្នា ត្រូវបានបង្ហាញនៅក្នុងជំពូកទី ៥។

ដំណើរការពីការដោះស្រាយសកម្មភាពជាយុទ្ធសាស្ត្រទៅនឹងតម្រូវការដែលបានរៀបរាប់ខាងលើបានមើលឃើញថា:

1. កំណត់សកម្មភាពនីមួយៗសម្រាប់ចំនុចអថេរនីមួយៗ
2. ចងក្រងក្រុមសកម្មភាពបំពេញបន្ថែម
3. លុបបំបាត់ភាពស្ទួន
4. រួមបញ្ចូលសកម្មភាពនីមួយៗដែលត្រូវគ្នានឹង "វិស័យយុទ្ធសាស្ត្រ"

ដូច្នោះហើយ ការវាយតម្លៃរបស់ រ៉េស្កូ(RESCO) ក៏បានផ្ដល់នូវវិស័យសកម្មភាពជាយុទ្ធសាស្ត្រយ៉ាងហោចណាស់បីដូចជា

a.អភិបាលកិច្ច

b.ប្រព័ន្ធសេវាកម្ម

c.ការកសាងសមត្ថភាព

ដោយពិចារណាលើអាទិភាពដែលបានលេចចេញពីការវិភាគស្ថានភាពនិងសក្ដានុពលនៃខ្សែសង្វាក់តម្លៃជំឡូងមី និងគោលដៅរបស់គម្រោង ខ្លេស៊ីដ្រា(CLESIDRA) សកម្មភាពជាយុទ្ធសាស្ត្រទាំងនេះត្រូវបានចងជាក្រុម ដោយយោងទៅតាមបីកម្រិតនៃអាទិភាព:

- អាទិភាពលេខ ១ សកម្មភាពដែលត្រូវគ្នានឹងគោលបំណង និងសំណើនៃផែនការការងាររបស់គម្រោង :ខ្លេស៊ីដ្រា(CLESIDRA) (សូមមើលប្រអប់ទី ១ អាទិភាពខ្ពស់" ហើយក្នុងពេលជាមួយគ្នានេះត្រូវគ្នានឹង (HP)" ដែលបានចង្អុលបង្ហាញដោយក្រុម រ៉េស្កូ(RESCO)។
- អាទិភាពលេខ ២) អាទិភាពខ្ពស់" សកម្មភាពដែលត្រូវគ្នានឹង :HP)" ដែលបានចង្អុលបង្ហាញដោយក្រុម រ៉េស្កូ(RESCO) ប៉ុន្តែមិនត្រូវបានមើលឃើញយ៉ាងច្បាស់ដោយគម្រោង ខ្លេស៊ីដ្រា(CLESIDRA) ហើយដែលនឹងតម្រង់ទិសផែនការរយៈពេលបីឆ្នាំក្នុងវេទិកា ផ្លាសិដ(PLASED) គណៈកម្មាធិការខ្សែសង្វាក់តម្លៃ និង **កុស្ស**(COSS)។
- អាទិភាពលេខ ៣) អាទិភាពមធ្យម" សកម្មភាពដែលត្រូវគ្នានឹង :MP)" ដែលបានចង្អុលបង្ហាញដោយក្រុម រ៉េស្កូ(RESCO)។

ប្រអប់ទី 1. **ផែនការ ខ្លេស៊ីដ្រា**(CLESIDRA)

**WP1 - ការបង្កើនជំនាញរបស់សង្គមស៊ីវិល (CSOs) អ្នកផលិត និងអាជ្ញាធរមូលដ្ឋាន (LAs) លើកិច្ចសន្ទនាជាមួយអ្នកពាក់ព័ន្ធ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមបែបបរិយាបន្ន**

A1.1 សិក្ខាសាលាកសាងសមត្ថភាពសម្រាប់ CSOs លើការចូលរួមយ៉ាងសកម្មក្នុងដំណើរការសម្រេចចិត្ត និងកិច្ចសន្ទនាជាមួយពាក់ព័ន្ធ។

A1.2 សិក្ខាសាលាកសាងសមត្ថភាពលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមបែបបរិយាបន្ន ការប្រកួតប្រជែង និងនិរន្តរភាពខ្សែសង្វាក់តម្លៃ។

A1.3 សិក្ខាសាលាកសាងសមត្ថភាព និងការគាំទ្រដើម្បីលើកកម្ពស់សមត្ថភាព CSOs (អភិបាលកិច្ចផ្ទៃក្នុង ផលប៉ះពាល់ ការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ ការតស៊ូមតិ ការបង្កើត និងការគ្រប់គ្រងគម្រោង)

A.1.4 សិក្ខាសាលាកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ CSOs លើបច្ចេកទេស/វិធីសាស្ត្រតម្លៃប្រកបដោយនិរន្តរភាព ការអភិរក្សធនធានធម្មជាតិ និងសន្តិសុខកសិករខ្នាតតូច (រួមទាំងសិទ្ធិកាន់កាប់ដីធ្លី)

**WP2** - ការបង្កើតជាវេទិកា ផ្លាសិដ(**PLASED**) ជាមួយអ្នកពាក់ព័ន្ធ

A2.1: ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកា ផ្លាសិដ(PLASED)

A2.2 ការចាប់ផ្តើមវេទិកា ផ្លាសិដ(PLASED) និងការអនុវត្តសកម្មភាពជាយុទ្ធសាស្រ្ត

A2.3: ការអភិវឌ្ឍ ការបោះពុម្ព និងការផ្សព្វផ្សាយសៀវភៅស្តីពីបទពិសោធន៍ ផ្លាសិដ(PLASED)

**WP3 - ការរៀបចំអោយមានការចូលរួមពីភាគីទាំងអស់នៃយុទ្ធសាស្រ្ត (STRAT) សម្រាប់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃបែបប្រកួតប្រជែង បរិយាបន្ន និរន្តរភាព និងភាពធន់**

**WP4 - ការបង្កើតប្រព័ន្ធសេវាកម្មដ៏ទូលំទូលាយ កុស្ស**(COSS)

A4.1 ការគូសប្លង់ និងការវិភាគរបស់អ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តរតនគិរី

A4.2 ជំនួយបច្ចេកទេសសម្រាប់រចនា កុស្ស(COSS)

A4.3 ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម កុស្ស(COSS)

A4.4 ការកសាងសមត្ថភាពដើម្បីកែលម្អជំនាញរបស់អ្នកផ្តល់សេវា និងដោះស្រាយចន្លោះប្រព័ន្ធសេវាកម្ម

A4.5 ការរៀបចំចាប់ផ្តើមប្រព័ន្ធ កុស្ស(COSS) និងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ កុស្ស(COSS) ដែលបានជ្រើរើស (ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ភាគីទី៣)

លទ្ធផលដំបូងនៃការវាយតម្លៃ រ៉េស្កូ(RESCO) គឺការកំណត់អត្តសញ្ញាណនៃចក្ខុវិស័យយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃដំឡូងមីដែលត្រូវសម្រេចនៅឆ្នាំ២០៣០ និងមាន "ការបង្កើនតម្លៃដំឡូងមី និងបង្កើនការលក់នៅលើទីផ្សារខេត្ត និងថ្នាក់ជាតិចំនួន ៤០% ដោយផ្តល់ការងារជាចម្បងដល់ប្រជាជនដែលខ្វះខាតបំផុត និងរាប់បញ្ចូល គុណសម្បត្តិប្រកួតប្រជែងរបស់ខ្លួន ដែលមានលក្ខណៈប្លែកពីគេ និងតម្លៃដ៏ច្រើនលើសលប់។ ដូចការពិត ដំឡូងមីរតនគិរី

អាចត្រូវបានបង្ហាញជាផលិតផល ដែលមានលក្ខណៈពិសេសដែលត្រូវបានកោតសរសើរ និងមានសមត្ថភាពក្នុងការផ្គត់ផ្គង់តម្រូវការអតិថិជនជាមួយនឹងបរិមាណដ៏ច្រើនរបស់វា។

## *5.3.* គោលការណ៍យុទ្ធសាស្ត្រណែនាំ និងផែនការសកម្មភាពលម្អិត

*គោលការណ៍យុទ្ធសាស្ត្រណែនាំ ត្រូវបានពិពណ៌នាដោយយោងទៅលើ*

⊗ អាទិភាពដូចដែលបានកំណត់ខាងលើ

⊗ វិស័យយុទ្ធសាស្ត្រ៖ អភិបាលកិច្ច សេវាកម្ម និងការកសាងសមត្ថភាព

ហើយវាត្រូវបានបែងចែកជា៖

⊗ សកម្មភាពសំដៅកម្រិតខ្សែសង្វាក់តម្លៃជាច្រើន (AM) ដែលរួមបញ្ចូលសកម្មភាពដែលស្រដៀងគ្នាមានក្នុងខ្សែសង្វាក់តម្លៃទាំងអស់

⊗ សកម្មភាពសំដៅកម្រិតខ្សែសង្វាក់តម្លៃដែលជាក់លាក់ ហើយខ្សែសង្វាក់តម្លៃនោះគឺជំឡូងមី

| អាទិភាពទី ១ |
|---|

**AM កម្រិតខ្សែសង្វាក់តម្លៃច្រើន**

**AM1.1: អភិបាលកិច្ច**

**AM1.11:** បង្កើត ផ្លាសិដ(**PLASED**)) (វេទិកាពហុភាគីអចិន្ត្រៃយ៍សម្រាប់ការពិភាក្សា និងការចូលរួមសម្រេចចិត្ត) ដែលជាយន្តការសម្រាប់លើកកម្ពស់កិច្ចសន្ទនាសង្គម និងរក្សាគុណសម្បត្តិប្រកួតប្រជែង និងបង្កើតការងារ តាមរយៈ ៖

ការផ្តល់ជំនួយបច្ចេកទេសក្នុងការរចនា និងការចាប់ផ្តើមវេទិកាផ្លាសិដ(**PLASED**))

(a) គាំទ្រសកម្មភាពអាទិភាពដូចជា

a1: ការព្រាងយុទ្ធសាស្ត្រទីផ្សារតំបន់

a2: សហការជាមួយរដ្ឋាភិបាលសម្រាប់ការកែលម្អការអនុវត្តផែនការរបស់រដ្ឋាភិបាល និងការគាំទ្រសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលចង់រីកចម្រើន និងមានលក្ខណៈជាផ្លូវការ

*b)* គាំទ្រការកសាងសម្ព័ន្ធភាពជាមួយភាគី និងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត

**AM1.12**: ការបោះពុម្ព និងរចនាសៀវភៅស្តីពី ផ្លាសិដ(PLASED))

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពរបស់ ខ្លេស៊ីដ្រា(CLESIDRA)) ចំនុច WP2 (A.2.3)**

**AM1.2: សេវាកម្ម**

**AM1.21** បង្កើតប្រព័ន្ធ កុស្ស(COSS) (ប្រព័ន្ធសេវាកម្មដ៏ទូលំទូលាយ) សម្រាប់ការផ្តល់សេវាកម្មសេដ្ឋកិច្ចសង្គម ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល តាមរយៈ៖

ការគូសផែនទី និងការវិភាគរបស់អ្នកផ្តល់សេវា/ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តរតនគិរី

(a) ជំនួយបច្ចេកទេសសម្រាប់ការរចនា កុស្ស(COSS)

(b) ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសដល់ការចាប់ផ្តើម កុស្ស(COSS)

ការចាប់ផ្តើម កុស្ស(COSS) និងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកប្រើប្រាស់ កុស្ស(COSS) ដែលបានជ្រើសរើស (ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ភាគីទីបី)

***សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាពចំនុច WP4 (A4.4)***

**AM1.22**: ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មធុរកិច្ច និងលទ្ធភាពទទួលបានពួកវា ដោយផ្តោតអាទិភាពលើចំណុចខាងក្រោម៖

សេវាកម្មបច្ចេកទេស រដ្ឋបាល និងសេវាស្ថាប័ន

- ទីផ្សារ/ពាណិជ្ជកម្ម
- ជំនួយក្នុងការអភិវឌ្ឍន៍សហករណ៍ កិច្ចសហប្រតិបត្តិការ/បណ្តាញ
- ជំនួយក្នុងការអភិវឌ្ឍន៍សម្ព័ន្ធភាព/សមាគម

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP4 (A4.4)**

**AM1.3: ការកសាងសមត្ថភាព**

**AM1.31: កសាងសមត្ថភាពលើរដ្ឋបាលធុរកិច្ច និងផែនការ ដែលជាប្រយោជន៍ក្នុងការស្នើសុំមូលនិធិ និងឥណទាន**

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A14)**

## ខ្សែសង្វាក់តម្លៃដំឡូងមី

### A1.1 អភិបាលកិច្ច

**A1.1**: បង្កើតគណៈកម្មាធិការអភិវឌ្ឍដំឡូងមី ដោយផ្អែកលើអ្នកចូលរួមនៃក្រុម Focus Group (ក្រុមចំបង) និងក្រុមរងផ្លាសិដ(PLASED) ដែលមានតួនាទីដូចខាងក្រោម៖

(a) សម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកផលិត ដើម្បីបង្កើនតម្លៃ )កំណើនការលក់ចេញ(
(b) ការបង្កើតកិច្ចព្រមព្រៀងសម្រាប់ការទិញរួមគ្នាធាតុដើម និងឬ ការចែករំលែកឧបករណ៍/ប្រើប្រាស់ជាមួយគ្នា និងការលក់រួមគ្នា សម្រាប់កាត់បន្ថយ)សកម្មភាពឈ្មួញកណ្តាល(
(c) ការកែលម្អលទ្ធភាពទទួលបានព័ត៌មានពីថ្នាក់ជាតិ
(d) ការធ្វើយុទ្ធនាការដើម្បីទាញការយកចិត្តទុកដាក់ពីរដ្ឋាភិបាលលើសារៈសំខាន់ និងគុណសម្បត្តិនៃការគាំទ្រខ្សែសង្វាក់តម្លៃដំឡូងមី
(e) ជំរុញរដ្ឋាភិបាលជាតិឱ្យពង្រឹងបទប្បញ្ញត្តិ និងផែនការគាំទ្រការការពារបរិស្ថាន (ការការពារធនធានធម្មជាតិ ការផ្លាស់ប្តូរទៅបរិយាកាសស្អាត និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព) និងផ្តល់ជំនួយ ដល់អ្នកដែលអនុវត្តអាជីវកម្ម និងគំនិតផ្តួចផ្តើមបង្កើតអាជីវកម្ម ។

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP2 (A2.2)**

**A1.2: សេវាកម្ម**

A1.21: ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មធុរកិច្ច និងលទ្ធភាពប្រើប្រាស់

- សេវាកម្មត្រួតពិនិត្យគុណភាព
- ការត្រួតពិនិត្យគុណភាពដី
- សេវាកម្មដឹកជញ្ជូន

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP4 (A44)**

*WP4 (A44)*

A1.22: គាំទ្រដលការផលិតអនុផលដូចជា៖

- ស្លឹកដំឡូងមីស្ងួត និងឫសស្ងួត
- នំដំឡូងមី
- ម្សៅដំឡូងមី (ខាប់)
- ម្សៅដំឡូងមី (ស្ងួត)
- ចំណីសត្វ
- ស្រា
- ម្សៅដំឡូងមីធម្មជាតិ

- ម្សៅដំឡូងមីកែច្នៃ សម្រាប់គោលបំណងឧស្សាហកម្មធ្វើក្រដាស និងវិស័យកាត់ដេរ ក៏ដូចជាឧស្សាហកម្មធ្វើកញ្ចក់ រោមសត្វ និងដីឥដ្ឋ។ ក្នុងនោះផងដែរក៏អាចកែច្នៃជាសារធាតុផ្អែម (ឱចស្រ្ទីន ម៉ូណូស៊្យូម និងក្លូតា) សម្រាប់ដាក់ក្នុងអាហារ និងបង្អែមរួមមានការ៉េម ចាហួយ ដំណាប់ ស្ករគ្រាប់ និងស្ករកៅស៊ូ។
- ខារ៉ាមែលដំឡូងមីដែលត្រូវបានប្រើជាសារធាតុពណ៌នៅក្នុងអាហារ ស្ករគ្រាប់ និងស្រា។
- អេតាណុលសម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្ម៖ វាអាចលាយជាមួយសាំង ឬប្រើជាអាល់កុលឧស្សាហកម្មដែលមានសារៈសំខាន់នៅក្នុងឧស្សាហកម្មឱសថ និងគ្រឿងសំអាង។

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP4 (A45)**

**A13: ការកសាងសមត្ថភាព**

A1.31: កសាងសមត្ថភាពសម្រាប់ការបង្កើនតម្លៃ ផលិតភាព ពាណិជ្ជកម្ម និងគុណភាព

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A14)**

A1.32: កសាងសមត្ថភាពសម្រាប់ការផលិតអនុផល ដូចដែលបានបង្ហាញនៅក្នុង A1.22 និងការដាំដុះសរីរាង្គ និងកសិ-បរិស្ថាន និងប្រព័ន្ធធារាសាស្ត្រនិរន្តរភាព

**សកម្មភាពនេះឆ្លើយតបទៅនឹងផែនការសកម្មភាព ខ្លេស៊ីដ្រា(CLESIDRA) ចំនុច WP1 (A14)**

## អាទិភាពលេខ២

## AM ខ្សែសង្វាក់តម្លៃច្រើនការម្រិត

**AM2.2: សេវាកម្ម**

**AM2.21: សេវាកម្មដែលសម្រួលដល់ការផ្គត់ផ្គង់គ្នារវាងតម្រូវការ និងកម្លាំងពលកម្ម**

### ខ្សែសង្វាក់តម្លៃដំឡូងមី

**A2.1: អភិបាលកិច្ច**

A2.11: ចរចាជាមួយរដ្ឋាភិបាលសម្រាប់៖

- ការសម្រេចបាននូវហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃ៖ ឃ្លាំងស្តុក ដឹកជញ្ជូន ផ្លូវថ្នល់ ទូរគមនាគមន៍ ប្រព័ន្ធអគ្គិសនី និងតម្រូវការប្រភពទឹក។

- ការសម្រេចបាននូវយន្តការហិរញ្ញវត្ថុជាក់លាក់សម្រាប់ខ្សែសង្វាក់តម្លៃ (ប្រព័ន្ធប្រាក់ឥណទាន)
- ការបង្កើនការស្រាវជ្រាវលើបច្ចេកវិទ្យាថ្មីៗ
- ផ្តល់ជំនួយ និងការលើកទឹកចិត្តសម្រាប់អាជីវកម្មដែលបង្កើនការងារ។

A2.12: លើកកម្ពស់ចីរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈ

- ជំរុញសាកលវិទ្យាល័យ និងសាលាវិជ្ជាជីវៈផ្តល់ការអប់រំអំពីរង្វង់នៃសេដ្ឋកិច្ច។
- ការបង្កើតប្រព័ន្ធត្រួតពិនិត្យលើការបំពុល និងការប្រើប្រាស់ធនធានទឹកក្នុងរយៈពេលវែង។

A2.2: **សេវាកម្ម**

A2.21: ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់ការចាប់ផ្តើមអាជីវកម្ម

A2.22 ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសម្រាប់ចីរភាពបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយផ្តោតអាទិភាពលើ៖

- ក្រុមហ៊ុនដែលប្រមូលសម្រាមតាមប្រភេទនៃសម្រាម និងមានការទុកដាក់បានត្រឹមត្រូវ
- គាំទ្រក្រុមហ៊ុនដែលមានការកែច្នៃសម្រាម និងការប្រើប្រាស់ឡើងវិញ

A2.23: សម្រួលលទ្ធភាពទទួលបានប្រាក់កម្ចី តាមរយៈ៖

- កិច្ចព្រមព្រៀងជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- កិច្ចព្រមព្រៀងជាមួយធនាគារមួយចំនួនសម្រាប់ការបង្កើតមូលនិធិធានា ឬឥណទានបង្វិលជាមួយនឹងការធានារួមគ្នា។ល។
- ការកែលម្អប្រព័ន្ធសុវត្ថិភាពដល់ប្រាក់កម្ចីសម្រាប់វិស័យធុរកិច្ច

A2.3: **ការកសាងសមត្ថភាព**

A2.31: ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគមន៍ក្នុងតំបន់ដើម្បីទទួលបានព័ត៌មានអំពីនិន្នាការតម្រូវការទីផ្សារ

A2.32: លើកកម្ពស់ការយល់ដឹងដល់កសិករក្នុងការធ្វើឱ្យសកម្មភាពរបស់ពួកគេមានលក្ខណៈជាផ្លូវការ

A2.33: កសាងសមត្ថភាពលើការការពារបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈ៖

- ការលើកកម្ពស់ការយល់ដឹង ការសម្រេចបាននូវការកសាងសមត្ថភាព និងគំនិតផ្តួចផ្តើមផ្សេងទៀតសម្រាប់ការបង្កើនការប្តេជ្ញាចិត្តលើការគ្រប់គ្រងបរិស្ថាន និងសេដ្ឋកិច្ចបៃតង រួមមានប្រព័ន្ធទឹក អគ្គិសនី និងការកាត់បន្ថយការចំណាយថ្លៃដើម ការបំភាយឧស្ម័ន $CO_2$; ការគ្រប់គ្រងកាកសំណល់; ការបង្កើនអាយុកាលប្រើប្រាស់នៃផលិតផល និងការប្រើប្រាស់វត្ថុធាតុដើមកែច្នៃ។ល។

- ពង្រឹងតួអង្គសំខាន់ក្នុងខ្សែសង្វាក់តម្លៃក្នុងការអនុវត្តល្អបំផុតលើការប្តេជ្ញាចិត្តលើការគ្រប់គ្រងបរិស្ថាន និងសេដ្ឋកិច្ចបៃតង។

A2.34: ការកសាងសមត្ថភាពក្នុង "របៀបគ្រប់គ្រងកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកផលិត

A2.35: ផ្តល់ការកសាងសមត្ថភាពសម្រាប់ជំនាញវិជ្ជាជីវៈផ្តោតលើការអភិវឌ្ឍដំឡូងមី ដោយយោងទៅលើ

- លទ្ធកម្មផលិតផល និងទីផ្សារទទួលខុសត្រូវ
- អ្នកលក់
- អ្នកដឹកជញ្ជូន
- ប្រតិបត្តិករឃ្លាំងស្តុកឥវ៉ាន់
- ប្រតិបត្តិករនៃបច្ចេកវិទ្យាឌីជីថល និងញាណវិទ្យាពីចម្ងាយថ្មី
- បច្ចេកទេសឯកទេសផ្នែកមនុស្សយន្ត និងស្វ័យប្រវត្តិកម្ម
- ឯកទេសបច្ចេកទេសផ្នែកបញ្ញាសិប្បនិម្មិត (AI)

DRAFT

## អាទិភាព លេខ ៣

## ខ្សែសង្វាក់តម្លៃដំឡូងមី

A3.1: **អភិបាលកិច្ច**

A31.1: ជំរុញការស្រាវជ្រាវដើម្បីស្វែងរកដំណោះស្រាយសម្រាប់ប្រព័ន្ធរង្វង់សេដ្ឋកិច្ច

A31.2: សម្រេចផែនការសម្រាប់អនុវត្តក្នុងស្ថានភាពបន្ទាន់ និងមានលក្ខណៈអភិវឌ្ឍន៍ដល់ដំឡូងមី (តម្លៃទំនិញ កម្លាំងពលកម្ម) តាមរយៈការបង្កើន៖ ការកាត់បន្ថយការបំភាយឧស្ម័ន ($CO2$) ការអភិវឌ្ឍគ្រាប់ពូជ ការដាំដុះបែបសរីរាង្គ កសិ-បរិស្ថាន និងប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។

A3.13: លើកកម្ពស់និរន្តរភាពសង្គម តាមរយៈការសហការជាមួយរដ្ឋាភិបាលសម្របសម្រួលប្រព័ន្ធបរិយាបន្នដោយផ្អែកទៅលើរូបរាងកាយសម្បទានៃបុគ្គលនីមួយៗ និងផ្លូវចិត្តរបស់ពួកគេ

A32: **សេវាកម្ម**

A3.21: ធ្វើឱ្យប្រសើរឡើងនូវសេវាកម្មជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដូចជា៖

- ម៉ាស៊ីនសម្ងួត
- ឧបករណ៍សម្អាត និងលាងដំឡូងមី

- ឧបករណ៍សម្រាប់កែច្នៃដំឡូងមី៖ ម៉ាស៊ីនកិនដំឡូងមី ម៉ាស៊ីនច្រោះដំឡូងមី ប្រព័ន្ធកាត់ទឹក និងសម្ងួត ម៉ាស៊ីនបកដំឡូងមី ម៉ាស៊ីនកិនដំឡូងមី ម៉ាស៊ីនកាត់បន្ទះដំឡូងមី។ល។
- នង្គ័លសម្រាប់រៀបចំដី
- ត្រាក់ទ័រ
- ម៉ាស៊ីនដាំដំឡូងមី
- ឧបករណ៍សម្រាប់ក្រោយដាំ ប្រមូលផល និងសម្រាប់ក្រោយប្រមូលផល
- ម៉ាស៊ីនច្រូតដំឡូងមី
- ម៉ាស៊ីនកិនដំឡូងមី
- ឧបករណ៍ និងគ្រឿងចក្រ
- សម្ភារៈសម្រាប់វេចខ្ចប់ (ប្រអប់ ថង់)

A3.22: លើកកម្ពស់និរន្តរភាពសង្គម តាមរយៈការគាំទ្រសហគ្រាសក្នុងការអនុវត្ត CSR

A3.23: ពង្រឹងសេវាកម្មដែលផ្តោតលើការការពារបរិស្ថាន តាមរយៈ

- ការអនុវត្តប្រព័ន្ធសម្រាប់ការទស្សន៍ទាយ និងការការពារហានិភ័យចំពោះប្រភពដើមរបស់សត្វពាហនៈ និងប្រភពដើមនៃធម្មជាតិ។
- ការផ្តល់សេវាកម្មសម្រាប់ការធ្វើវិញ្ញាបនប័ត្រជីវសាស្ត្រ។
- ការផ្តល់សេវាកម្មសម្រាប់ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីសរីរាង្គ។

### A3.3 **ការកសាងសមត្ថភាព**

A3.31: កសាងសមត្ថភាពលើនិរន្តរភាពសង្គម ដោយយោងជាពិសេសទៅលើ

- បុគ្គលដែលមានសមត្ថភាពរាងកាយ និងផ្លូវចិត្តផ្សេងៗពីគ្នា សម្រាប់ឱកាសការងារ។
- សមត្ថភាពលើទំនួលខុសត្រូវសង្គមសាជីវកម្ម (CSR)
- លើកតម្កើងស្ត្រីក្នុងឱកាសកាន់តំណែងសំខាន់ៗក្នុងការងារតម្លៃ អង្គការ និងស្ថាប័ន និងរួមទាំងស្ថាប័នសាធារណៈផងដែរ។

A3.32: សម្រេចយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងវប្បធម៌ប្រឆាំងនឹងអំពើហិង្សាលើស្ត្រី។

A3.33: លើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាពរបស់កសិករ និងសហគ្រាសធុនតូច និងមធ្យម (SMMEs) លើគុណសម្បត្តិនៃការអនុវត្តដំណោះស្រាយសម្រាប់ការការពារបរិស្ថាន។

DRAFT

Civil society Links and Empowerment for Socially Inclusive Development in Ratanakiri

FELCOSUMBRIA
Associazione di Comuni per lo Sviluppo Sostenibile

ILS LEDA

Building Community Voices

UPWD

ឯកសារនេះត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃគម្រោង CLESIDRA ដែលទទួលបានជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញនៅទីនេះមិនចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបទេ ហើយក៏មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់តំណាងរបស់សហភាពអឺរ៉ុបដែរ។ សហភាពអឺរ៉ុបមិនទទួលខុសត្រូវចំពោះមតិយោបល់របស់អ្នកនិពន្ធទេ។

This project is funded by
the European Union